**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ៖ ៤៦៣
ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

**សាលក្រម**
លេខ៖ ១០ (ក្រ.ក)
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ៩:០០ នាទី ព្រឹក ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ជាប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤៦៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ដែលមាន៖

**១-ជនជាប់ចោទ៖** ឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម មុខរបរអាជីវករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] អូស្មាន់ (រ) ម្តាយឈ្មោះ កក់ សំ (រ) ប្រពន្ធឈ្មោះ [redacted] អាលីហ្វា មានកូនចំនួន ០២ នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ១៨ ខែ។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៥/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

ត្រូវបានចោទប្រកាន់ពីបទ រក្សាទុក ជួញដូរ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤២ កថាខណ្ឌទី៣ ចំណុច២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកមេធាវី [redacted] លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

**២-ជនជាប់ចោទ៖** ឈ្មោះ [redacted] សារុន ហៅគ្មុយ ភេទប្រុស អាយុ៣០ ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] ពឿន (វ) ម្តាយឈ្មោះ [redacted] ឃឿន (វ) នៅលីវ ទោសពីមុនគ្មាន។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៥/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**៣-ជនជាប់ចោទ៖** ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] (វ) ម្តាយឈ្មោះ [redacted] សុធា (វ) នៅលីវ ទោសពីមុនគ្មាន។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២១/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

ត្រូវបានចោទប្រកាន់ពីបទ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

**៤-ជនជាប់ចោទ៖** ឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] គ្រីយ៉ា (វ) ម្តាយឈ្មោះ [redacted] ស្រីណេ (វ) នៅលីវ ទោសពីមុនគ្មាន។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦២៣/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

**៥-ជនជាប់ចោទ៖** ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] ផុន (វ) ម្តាយឈ្មោះ [redacted] ចាន់ (វ) នៅលីវ ទោសពីមុនគ្មាន។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៩/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

**៦-ជនជាប់ចោទ៖** ឈ្មោះ [redacted] ថារ: ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] ឪពុកឈ្មោះ [redacted] វង្ឋា (វ) ម្តាយឈ្មោះ [redacted] កំសត់ (វ) នៅលីវ ទោសពីមុនគ្មាន។

**ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦១៧/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។**

ត្រូវបានចោទប្រកាន់ពីបទ រក្សាទុក **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

លោកមេធាវី [redacted] ជាមេធាវីកាពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] ថារ:។



Scanned with CamScanner

**៧-ជនជាប់ចោទ៖** ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted]។ (ក្រៅឃុំ)

ត្រូវបានចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**បានឃើញ៖** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ៣៣៣ ដ.ស.ស/២៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**បានឃើញ៖** ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១៩១៦ ដ.ស.ព/២៣ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**បានឃើញ៖** ដីកាដំណោះស្រាយលេខ៖ ៣៩៨/២៣ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ៖

កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នៅចំណុចភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានជន សង្ស័យឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ បានលក់ថ្នាំញៀនឱ្យបុរសម្នាក់មិនស្គាល់អត្តសញ្ញាណ ចំនួន០១ កញ្ចប់ តម្លៃ៣០,០០០ រៀល បន្ទាប់មកក៏មានសមត្ថកិច្ចចេញមកឃាត់ខ្លួនឈ្មោះ [redacted] ខ្លឹង ហើយឆែកឆេររកឃើញមានថ្នាំញៀនប្រភេទ មេតំហ្វេតាមីន ចំនួន៧៩ កញ្ចប់ នៅលើខ្លួនឈ្មោះ [redacted] ខ្លឹង។ ឈ្មោះ [redacted] ខ្លឹង បានសារភាព ថាថ្នាំញៀនទាំងនោះ ខ្លួនទិញពីឈ្មោះ [redacted] ពឿន។ បន្ទាប់មកសមត្ថកិច្ចបានបន្តធ្វើការសាកសួរឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថារៈ ពួកគេបានសារភាព ថាពួកគេជាអ្នកធ្វើការនៅក្នុងការ៉ាស់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ហើយតែងតែឃើញមានគេចូលមកទិញថ្នាំញៀនពីឈ្មោះ លី ខ្លឹង ជាញឹកញាប់ មិនតែប៉ុណ្ណោះ ឈ្មោះ [redacted] ខ្លឹង ក៏បានឱ្យថ្នាំញៀនទៅពួកគេប្រើប្រាស់ផងដែរ។ បន្ទាប់មកសមត្ថកិច្ច ក៏បានបន្តឃាត់ខ្លួនជនសង្ស័យទាំង០៦ នាក់ បន្តទៀត ហើយបានដកហូតថ្នាំញៀនពីឈ្មោះ [redacted] ថារៈ ចំនួន០៦ កញ្ចប់តូច ទម្ងន់២.៤៦ ក្រាម, ឈ្មោះ [redacted] ហាក់ ចំនួន០៣ កញ្ចប់តូច ទម្ងន់ ០.៦១ ក្រាម, ឈ្មោះ [redacted] សុខលី ចំនួន០១ កញ្ចប់តូច ទម្ងន់០.២២ ក្រាម។ បន្ទាប់មកសមត្ថកិច្ច បានបញ្ជូនខ្លួនឈ្មោះ [redacted] ខ្លឹង, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] ថារៈ និងឈ្មោះ [redacted] ស៊ីណា មកស្នងការនគរបាលខេត្តកំពង់ឆ្នាំង ធ្វើតេស្តទឹកនោមរកឃើញសារធាតុញៀននៅក្នុងទឹកនោមឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] ថារៈ និងឈ្មោះ [redacted] ស៊ីណា។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង បានឆ្លើយថា ៖ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចចាប់យកជាក់ស្តែងនៅការ៉ាស់សាំងខ្លួននោះគឺមិនមែនជាថ្នាំញៀនរបស់ខ្លួនទេ ខ្លួនក៏ពុំបានដឹងថាថ្នាំញៀននេះនៅការ៉ាស់សាំងរបស់ខ្លួនដែរ តែចំពោះការ៉ាស់សាំង ជាការ៉ាស់សាំងខ្លួនមែន ប៉ុន្តែខ្លួនបានជួលឈ្មោះ [redacted] ថារៈ ឱ្យមកលក់សាំងឱ្យខ្លួន និងសម្រាក នៅការ៉ាស់សាំងនេះ ដើម្បីមើលការខុសត្រូវ ខ្លួនពុំបានស្នាក់នៅការ៉ាស់សាំងនេះទេ ខ្លួនគ្រាន់តែមកមើលការខុសត្រូវតែមួយភ្លែតៗនៅពេលព្រឹក ព្រោះខ្លួនត្រូវមកដាស់កូនចៅរាល់ព្រឹក ខ្លួនមានការ៉ាស់សាំងចំនួន ០២

(ពីរ) ខ្លួនជួលមនុស្ស ០២នាក់ ដើម្បីសម្រាក និងលក់ និងនៅមើលការខុសត្រូវការ៉ាស់សាំងទី១ ដែលមានឈ្មោះ [redacted] នៅលក់ និងសម្រាកមើលការខុសត្រូវ នៅភូមិដើមពពេល ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ត្រឡាច ចំពោះការ៉ាស់សាំទី២ នៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលការ៉ាស់សាំងនេះ ឈ្មោះ [redacted]ថាវៈ នៅលក់ និងសម្រាកនៅទីនេះផងដែរ។ ដោយឡែកនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១២ និង៣០នាទីថ្ងៃត្រង់ សមត្ថកិច្ចបានឃាត់ខ្លួន និងកូនចៅខ្លួនឈ្មោះ [redacted] ថាវៈ នៅការ៉ាស់សាំងភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច នេះថាបានពាក់ព័ន្ធរឿងគ្រឿងញៀន និងបានឆែកឆេរឃើញមានថ្នាំញៀនជាច្រើនកញ្ចប់នៅក្រោមតុគិតលុយរបស់ខ្លួននោះ ខ្លួនពុំបានដឹងទេថាថ្នាំញៀននៅទីនេះទេ ហើយថ្នាំញៀននេះពុំមែនជារបស់ខ្លួន ហើយខ្លួនសូមបដិសេធចោលស្រុងចំពោះថ្នាំញៀន ដែលសមត្ថកិច្ចបានឆែកឃើញនេះ ព្រោះខ្លួនពុំដែលស្នាក់នៅការ៉ាស់សាំងនេះទេ ខ្លួនគ្រាន់តែបានមើលការខុសត្រូវតែមួយភ្លែត១តែប៉ុណ្ណោះ។ ខ្លួនពុំដែលប្រើប្រាស់ថ្នាំញៀនទេ ហើយខ្លួនក៏ពុំដែលលក់ថ្នាំញៀនដែរ ខ្លួនពុំបានដឹងរឿងអ្វីទាំងអស់។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូត ដូចជាលុយដុល្លារចំនួន ១៣២៤ $ (មួយពាន់បីរយម្ភៃបួន) ដុល្លាររអាមេរិក និងប្រាក់រៀលចំនួន ១,១២៥,០០០ ៛ (មួយលានដប់ពីរម៉ឺនប្រាំពាន់) រៀល ទូរស័ព្ទម៉ាក OPPO (ពុំចាំពណ៌) មួយគ្រឿង ទូរស័ព្ទម៉ាកអិនចុចពិល(ខូច) មួយគ្រឿង និងម៉ូតូម៉ាកហុងដាសេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំស្លាកលេខ មួយគ្រឿង និងថ្នាំញៀនចំនួន ៨៨ កញ្ចប់។

-ជនជាប់ចោទឈ្មោះ [redacted] សារុន បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted]ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ខ្លួនជាមិត្តភ័ក្តឈ្មោះ[redacted]សុខលី ឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថាវៈ ហើយឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted] ខ្លឹង ខ្លួន និងមិត្តភ័ក្តឈ្មោះ [redacted] ស៊ីណា ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយរបស់ឈ្មោះ [redacted] សុខលី និងឈ្មោះ[redacted]ហាក់ ហើយឈ្មោះ [redacted]សុខលី តែងតែបបួលខ្លួនមកលេងបងជីដូនមួយរបស់គេ ហើយបានបបួលខ្លួនប្រើប្រាស់ថ្នាំញៀនទៀតផង ខ្លួនប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះខាងលើនេះ នៅការ៉ាស់សាំងដែលឈ្មោះ ហាក់ បានធ្វើការនោះបានចំនួន ៣ដង ខ្លួនមិនដឹងថានរណាជាអ្នកទិញថ្នាំញៀនទេ ខ្លួនគ្រាន់តែឈ្មោះ [redacted] សុខលី បបួលមកប្រើប្រាស់ តែពុំដែលឱ្យខ្លួនចេញលុយទេ។ ពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងជីដូនមួយរបស់ឈ្មោះ[redacted]សុខលី មកធ្វើការនៅជិតនេះទេ ទើបខ្លួនប្រើប្រាស់។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted]ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ខ្លួនជាមិត្តភក្តិឈ្មោះ [redacted]សុខលី, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថាវៈ ហើយឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted] ខ្លឹង ខ្លួន និងមិត្តភក្តឈ្មោះ [redacted] សារុន ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយរបស់ឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted]ហាក់ ហើយឈ្មោះ [redacted]សុខលី តែងតែបបួលខ្លួនមកលេងបងជីដូនមួយរបស់គេ ហើយ



Scanned with CamScanner

បានបបួលខ្លួនប្រើប្រាស់ថ្នាំញៀនទៀតផង ខ្លួនប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះអ្នកខាងលើ ដែលខ្លួនបានរៀបរាប់នោះនៅការ៉ាស់សាំងដែលឈ្មោះ ហាក់ បានធ្វើការនោះ បានចំនួន០៥ដង ខ្លួនមិនដឹងថានរណាជាអ្នកទិញថ្នាំញៀនទេ ខ្លួន គ្រាន់តែឈ្មោះ [redacted]សុខលី បបួលមកប្រើប្រាស់ តែពុំដែលឱ្យខ្លួនចេញលុយទេ។ ពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងជីដូនមួយរបស់ឈ្មោះ [redacted]សុខលី មកធ្វើការនៅជិតនេះទេ ទើបខ្លួនប្រើប្រាស់។

-ជនជាប់ចោទឈ្មោះ [redacted] សុខលី បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុអោយខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យតែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ហើយស្គាល់គាត់តាមរយៈបងប្រុសខ្លួននៅត្បូងឃ្មុំ ហើយបងប្រុសជីដូនមួយខ្លួនឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted]ខ្លឹង ខ្លួន និងមិត្តភក្តឈ្មោះ [redacted]ស៊ីណា និងឈ្មោះ [redacted] សារុន ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយខ្លួនឈ្មោះ [redacted] ហាក់ ហើយបងជីដូនមួយខ្លួនបានបបួលពួកខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួន ២ដង នៅការ៉ាស់សាំង ដែលគាត់លក់នេះ ហើយរាល់ពេលទិញថ្នាំ គឺគាត់ជាអ្នកទៅទិញ ដោយពួកខ្លួនបានចូលលុយគ្នាម្នាក់អស់ចំនួន ១០,០០០៛ (មួយម៉ឺន) រៀល បាន១កញ្ចប់។ ខ្លួនមិនស្គាល់ថា បងខ្លួនទិញថ្នាំញៀនពីអ្នកណាទេ គ្រាន់តែធ្លាប់គាត់ប្រាប់ថា ទិញពីឈ្មោះ[redacted]ពឿន តែប៉ុណ្ណោះ។ ពីមុនមក ខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងខ្លួនមកធ្វើការនៅជិតនេះទេទើបខ្លួនប្រើប្រាស់។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូតដូចជា ថ្នាំញៀនចំនួន ០១ កញ្ចប់តូច។

-ជនជាប់ចោទឈ្មោះ [redacted] ហាក់ បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យតែប៉ុណ្ណោះ។ ខ្លួនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ[redacted]ខ្លឹង បានប្រហែល ៥ខែ ហើយពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែខ្លួនមកធ្វើការនៅទីនេះទេ ហើយក៏បានស្គាល់ឈ្មោះ [redacted] ថារ: ហើយឈ្មោះ [redacted] ថារ: ក៏បានបបួលខ្លួនប្រើប្រាស់នៅការ៉ាស់សាំងដែលឈ្មោះ [redacted] ថារ: ធ្វើការ។ ខ្លួនបានប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ថារ: បានប្រហែល ៤ ទៅ ៥ដង ខ្លួនពុំធ្លាប់ស្គាល់ឈ្មោះ [redacted] ពឿន ពីមុនទេ ទើបតែខ្លួនមកធ្វើការនៅទីនេះ ខ្លួនបានស្គាល់ ហើយខ្លួនស្គាល់តាមរយៈឈ្មោះស្រេង ថារ: ទេ ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted]ពឿន បានចំនួន ៥ដង។ បន្ទាប់មកឈ្មោះ[redacted]ពឿន ចេះតែឧស្សាហ៍មកចាក់សាំង ហើយជជែកលេងជាមួយខ្លួនពីនេះពីនោះ ហើយគាត់ក៏បានប្រាប់ខ្លួនថាគាត់មានលក់ថ្នាំញៀន បានប្រហែល ២ ទៅ ៣ថ្ងៃ ខ្លួនក៏បានទាក់ទងទៅឈ្មោះ[redacted]ពឿន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់ពីរនាក់ឈ្មោះ [redacted]សារុន បានចំនួន ៤ ដង ហើយខ្លួនទិញថ្នាំញៀនម្តងអស់ ២០,០០០ (ពីរម៉ឺន)រៀល ទៅ ៣០,០០០ (បីម៉ឺន) រៀល យកមកប្រើប្រាស់តែពីរនាក់ឈ្មោះ [redacted] សារុន ទេ។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៧យប់ ឈ្មោះ [redacted] ថារ: បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ពឿន បានជិះម៉ូតូចូលមកការ៉ាស់សាំង ហើយបានយកថ្នាំញៀនជាច្រើនកញ្ចប់មកផ្ញើវា ដោយប្រាប់ថាទៅទិញបង្អែមញ៉ាំមួយភ្លែត ហើយវាក៏បានទទួលទុកឱ្យ រួចវាបានយកទៅ



Scanned with CamScanner

ដាក់នៅក្រោមគុគិតលុយរបស់ថៅកែខ្លួននៅការ៉ាស់សាំងដែលវាលក់នោះ បន្ទាប់មកនៅយប់ដដែលនោះវាបានអង្គុយចាំឈ្មោះ [redacted] ពឿន មកយកថ្នាំញៀន ប៉ុន្តែមិនឃើញគេមកយកថ្នាំញៀនសោះ រហូតឈានចូលដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០នាទីរសៀល មានសមត្ថកិច្ចចុះមកឆែកឆេរ និងបានចាប់យកជាក់ស្តែងនៅការ៉ាស់សាំងដែលលក់ឱ្យឈ្មោះ [redacted] ខ្លឹង នោះគឺជាថ្នាំញៀនរបស់ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុប្រហែល ២៣ ឆ្នាំទេ ខ្លួនសូមបញ្ជាក់ថា ថ្នាំញៀនដែលចាប់បាននៅការ៉ាស់សាំងរបស់ថៅកែខ្លួនឈ្មោះ [redacted] ខ្លឹង នោះគឺពុំមែនជាថ្នាំញៀនរបស់គាត់ទេ ហើយខ្លួនក៏ពុំដែលសមគំនិត ឬក៏លក់ដូរអ្វីទេ ហើយថៅកែខ្លួនក៏ពុំដែលស្គាល់ឈ្មោះ [redacted] ពឿន ដែរ។ សូមបញ្ជាក់ថា ថៅកែខ្លួនពុំដែលសម្រាកនៅការ៉ាស់សាំងនេះ គាត់គ្រាន់តែមកមើលពេលព្រឹកមួយភ្លែតៗតែប៉ុណ្ណោះ។

-ជនជាប់ចោទឈ្មោះ [redacted] ថាវៈ បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ។ ចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែស្គាល់ឈ្មោះ [redacted] ពឿន បានប្រហែលមួយខែ គឺកាលពីអំឡុងខែឧសភា ហើយស្គាល់តាមរយៈមិត្តភ័ក្ត។ បន្ទាប់មកឈ្មោះ [redacted] ពឿន ចេះតែឧស្សាហ៍មកចាក់សាំង ហើយជជែកលេងជាមួយខ្លួនពីនេះពីនោះ ហើយគាត់ក៏បានប្រាប់ខ្លួនថា គាត់មានលក់ថ្នាំញៀន បានប្រហែល ២ ទៅ ៣ថ្ងៃ ខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] ពឿន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់ពីរនាក់ឈ្មោះ [redacted] សារុន បានចំនួន ៤ ដង ហើយខ្លួនទិញថ្នាំញៀនម្តងអស់ ២០,០០០ (ពីរម៉ឺន) រៀល ទៅ ៣០,០០០ (បីម៉ឺន) រៀល យកមកប្រើប្រាស់តែពីរនាក់ឈ្មោះ [redacted] សារុន ទេ។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៧ យប់ ឈ្មោះ [redacted] ពឿន បានជិះម៉ូតូចូលមកការ៉ាស់សាំង ហើយបានយកថ្នាំញៀនជាច្រើនកញ្ចប់មកផ្ញើរខ្លួន ដោយប្រាប់ថាទៅទិញបង្អែមញ៉ាំមួយភ្លែត ខ្លួនក៏បានទទួលទុកឱ្យ រួចខ្លួនបានយកទៅដាក់នៅក្រោមតុគិតលុយរបស់ថៅកែខ្លួននៅការ៉ាស់សាំង បន្ទាប់មកនៅយប់ដដែលនោះខ្លួនបានអង្គុយចាំឈ្មោះ ពឿន មកយកថ្នាំញៀន ប៉ុន្តែមិនឃើញគេមកយកថ្នាំញៀនសោះ រហូតឈានចូលដល់ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០ នាទីរសៀល មានសមត្ថកិច្ចចុះមកឆែកឆេរ និងបានចាប់យកជាក់ស្តែងនៅការ៉ាស់សាំងដែលខ្លួនលក់ឱ្យឈ្មោះ [redacted] ខ្លឹង នោះគឺជាថ្នាំញៀនរបស់ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុប្រហែល ២៣ ឆ្នាំ ខ្លួនសូមបញ្ជាក់ថា ថ្នាំញៀនដែលចាប់បាននៅការ៉ាស់សាំងរបស់ថៅកែខ្លួនឈ្មោះ [redacted] ខ្លឹង គឺពុំមែនជាថ្នាំញៀនរបស់គាត់ទេ ហើយខ្លួនក៏ពុំដែលធ្លាប់ប្រើប្រាស់ ឬក៏លក់ដូរអ្វីទេ ហើយថៅកែខ្លួនក៏ពុំដែលស្គាល់ឈ្មោះ [redacted] ពឿន ដែរ។ សូមបញ្ជាក់ថា ថៅកែខ្លួនពុំដែលសម្រាកនៅការ៉ាស់សាំងនេះ គាត់គ្រាន់តែមក មើលពេលព្រឹកមួយភ្លែតៗតែប៉ុណ្ណោះ។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូតដូចជាទូរស័ព្ទម៉ាក OPPO ពណ៌ក្រហម មួយគ្រឿង និងថ្នាំញៀនចំនួន ៨៨ កញ្ចប់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ជនជាប់ចោទឈ្មោះ [redacted] ថាវៈ, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] សុខលី ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា និងឈ្មោះ [redacted] សារុន ពិតជាបានប្រព្រឹត្តអំពើ

សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ [redacted] ពឿន ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាដកម៉ែន ដូច្នេះតំណាងអយ្យការ សូមរក្សាការចោទប្រកាន់ទុកនៅដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជននេះតាមច្បាប់។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ចម្លើយរបស់ជនជាប់ចោទដែលឆ្លើយនៅទីនេះ គឺមានភាពស៊ីសង្វាក់គ្នា ដោយនេះគឺជាចម្លើយដែលបង្ហាញពីការពិតខ្លាំង។ ដូច្នេះសូមឱ្យក្រុមប្រឹក្សាពិចារណា។ ចំពោះកំណត់ហេតុដែលឆ្លើយនៅប៉ូលីស គឺកូនក្តីខ្លួនបដិសេធទាំងអស់ ហើយគ្រឿងញៀនទាំងនោះ គឺជារបស់ឈ្មោះ [redacted] ពឿន។ សូមសំណូមពរឱ្យក្រុមប្រឹក្សាចាត់របៀបដើម្បីសួរតទល់រវាងកូនក្តីខ្លួន និងប៉ូលីស ហើយករណីដែលក្រុមប្រឹក្សានៅតែសម្រេចអំពីអង្គសេចក្តី ខ្លួនស្នើសុំឱ្យសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ខ្លឹង រួចខ្លួនពីបទចោទ ដោយសារកូនក្តីខ្លួនមិនបានដឹងពីគ្រឿងញៀនទាំងនោះឡើយ ហើយលទ្ធផលតេស្តទឹកនោមក៏មិនមានឃើញវិជ្ជមានទៀត។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ខ្លួនសូមឱ្យក្រុមប្រឹក្សាសម្រេចដល់កូនក្តីខ្លួន ដោយពិចារណាអំពីចរិតលក្ខណៈនៃបទល្មើស។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ចម្លើយដែលកូនក្តីខ្លួនបដិសេធ គឺសមហេតុផល។ ដូច្នេះ សូមឱ្យក្រុមប្រឹក្សាសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង ដោយសារតែកូនក្តីខ្លួនជាអនីតិជន ហើយសារធាតុសុទ្ធនៃសារធាតុញៀនមានចំនួនតិច។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង៖ ខ្លួនសូមឱ្យតុលាការសម្រេចលើកលែងទោសដល់ខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុន៖ ខ្លួនសូមឱ្យតុលាការសម្រេចលើកលែងទោសដល់ខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា៖ ខ្លួនសូមឱ្យតុលាការសម្រេចលើកលែងទោសដល់ខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខលី៖ ខ្លួនសូមឱ្យតុលាការជួយផ្តល់ស្ថានសម្រាលទោសដល់ខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ហាក់៖ ខ្លួនសូមឱ្យតុលាការជួយផ្តល់ស្ថានសម្រាលទោសដល់ខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] ថារ៉ះ៖ ខ្លួនសូមឱ្យតុលាការជួយផ្តល់ស្ថានសម្រាលទោសដល់ខ្លួនផង។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ



Scanned with CamScanner

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នៅចំណុចភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង មានជន សង្ស័យឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ បានលក់ថ្នាំញៀនឱ្យបុរសម្នាក់មិនស្គាល់អត្តសញ្ញាណ ចំនួន០១ កញ្ចប់ តម្លៃ៣០,០០០ រៀល បន្ទាប់មកក៏មានសមត្ថកិច្ចចេញមកឃាត់ខ្លួនឈ្មោះ [redacted] ខ្លឹង ហើយឆែកឆេរ រកឃើញមានថ្នាំញៀនប្រភេទ មេតំហ្វេតាមីន ចំនួន៧៩ កញ្ចប់ នៅលើខ្លួនឈ្មោះ [redacted] ខ្លឹង។ ឈ្មោះ [redacted] ខ្លឹង បាន សារភាព ថាថ្នាំញៀនទាំងនោះ ខ្លួនទិញពីឈ្មោះ [redacted] ពឿន។ បន្ទាប់មកសមត្ថកិច្ចបានបន្តធ្វើការសាកសួរឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថារ: ពួកគេបាន សារភាព ថាពួកគេជាអ្នកធ្វើការនៅក្នុងការ៉ាស់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ហើយតែងតែឃើញមានគេចូលមក ទិញថ្នាំញៀនពីឈ្មោះ លី ខ្លឹង ជាញឹកញាប់ មិនតែប៉ុណ្ណោះ ឈ្មោះ [redacted] ខ្លឹង ក៏បានឱ្យថ្នាំញៀនទៅពួកគេប្រើប្រាស់ ផងដែរ។ បន្ទាប់មកសមត្ថកិច្ច ក៏បានបន្តឃាត់ខ្លួនជនសង្ស័យទាំង០៦ នាក់ បន្តទៀត ហើយបានដកហូតថ្នាំញៀន ពីឈ្មោះ [redacted] ថារ: ចំនួន០៦ កញ្ចប់តូច ទម្ងន់២.៤៦ ក្រាម, ឈ្មោះ [redacted] ហាក់ ចំនួន០៣ កញ្ចប់តូច ទម្ងន់ ០.៦១ ក្រាម, ឈ្មោះ [redacted] សុខលី ចំនួន០១ កញ្ចប់តូច ទម្ងន់០.២២ ក្រាម។ បន្ទាប់មកសមត្ថកិច្ច បានបញ្ជូនខ្លួន ឈ្មោះ [redacted] ខ្លឹង, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] ថារ: និងឈ្មោះ [redacted] ស៊ីណា មកស្នងការនគរបាលខេត្តកំពង់ឆ្នាំង ធ្វើតេស្តទឹកនោមរកឃើញសារធាតុញៀននៅក្នុងទឹកនោមឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] ថារ: និងឈ្មោះ [redacted] ស៊ីណា។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ខ្លឹង បានឆ្លើយថា ៖ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចចាប់យក ជាក់ស្តែងនៅ ការ៉ាស់សាំងខ្លួននោះគឺមិនមែនជាថ្នាំញៀនរបស់ខ្លួនទេ ខ្លួនក៏ពុំបានដឹងថាថ្នាំញៀននេះនៅការ៉ាស់សាំង របស់ខ្លួនដែរ តែចំពោះការ៉ាស់សាំង ជាការ៉ាស់សាំងខ្លួនមែន ប៉ុន្តែខ្លួនបានជួលឈ្មោះ [redacted] ថារ: ឱ្យមកលក់ សាំងឱ្យខ្លួន និងសម្រាក នៅការ៉ាស់សាំងនេះ ដើម្បីមើលការខុសត្រូវ ខ្លួនពុំបានស្នាក់នៅការ៉ាស់សាំងនេះទេ ខ្លួន គ្រាន់តែមកមើលការខុសត្រូវតែមួយភ្លែតៗនៅពេលព្រឹក ព្រោះខ្លួនត្រូវមកដាស់កូនចៅរាល់ព្រឹក ខ្លួនមានការ៉ាស់ សាំងចំនួន ០២ (ពីរ) ខ្លួនជួលមនុស្ស ០២នាក់ ដើម្បីសម្រាក និងលក់ និងនៅមើលការខុសត្រូវការ៉ាសសាំងទី១ ដែលមានឈ្មោះ ហាក់ នៅលក់ និងសម្រាកមើលការខុសត្រូវ នៅភូមិដើមពពេល ឃុំថ្មឥដ្ឋ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ត្រឡាច ចំពោះការ៉ាស់សាំទី២ នៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលការ៉ាស់ សាំងនេះ ឈ្មោះ [redacted] ថារ: នៅលក់ និងសម្រាកនៅទីនេះផងដែរ។ ដោយឡែកនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ១២ និង៣០នាទីថ្ងៃត្រង់ សមត្ថកិច្ចបានឃាត់ខ្លួន និងកូនចៅខ្លួនឈ្មោះ [redacted] ថារ: នៅការ៉ាស់សាំងភូមិ ការអត ឃុំពានី ស្រុកកំពង់ត្រឡាច នេះថាបានពាក់ព័ន្ធរឿងគ្រឿងញៀន និងបានឆែកឆេរឃើញមានថ្នាំញៀនជា ច្រើនកញ្ចប់នៅក្រោមតុគិតលុយរបស់ខ្លួននោះ ខ្លួនពុំបាទដឹងទេថាថ្នាំញៀននៅទីនេះទេ ហើយថ្នាំញៀននេះពុំមែនជា របស់ខ្លួន ហើយខ្លួនសូមបដិសេធចោលស្រុងចំពោះថ្នាំញៀន ដែលសមត្ថកិច្ចបានឆែកឃើញនេះ ព្រោះខ្លួនពុំដែល ស្នាក់នៅការ៉ាស់សាំងនេះទេ ខ្លួនគ្រាន់តែបានមើលការខុសត្រូវតែមួយភ្លែតៗតែប៉ុណ្ណោះ។ ខ្លួនពុំដែលប្រើប្រាស់ថ្នាំ



Scanned with CamScanner

ញៀនទេ ហើយខ្លួនក៏ពុំដែលលក់ថ្នាំញៀនដែរ ខ្លួនពុំបានដឹងរឿងអ្វីទាំងអស់។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូតដូចជាលុយដុល្លារចំនួន ១៣២៤ $ (មួយពាន់បីរយម្ភៃបួន) ដុល្លារអាមេរិក និងប្រាក់រៀលចំនួន ១,១២៥,០០០ ៛ (មួយលានដប់ពីរម៉ឺនប្រាំពាន់) រៀល ទូរស័ព្ទម៉ាក OPPO (ពុំចាំពណ៌) មួយគ្រឿង ទូរស័ព្ទម៉ាកអិនចុចពិល(ខូច) មួយគ្រឿង និងម៉ូតូម៉ាកហុងដាសេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំស្លាកលេខ មួយគ្រឿង និងថ្នាំញៀនចំនួន ៨៨ កញ្ចប់។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សារុន បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ខ្លួនជាមិត្តភ័ក្តឈ្មោះ [redacted] សុខលី ឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថាវៈ ហើយឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted] ខ្លឹង ខ្លួន និងមិត្តភ័ក្តឈ្មោះ [redacted] ស៊ីណា ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយរបស់ឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] ហាក់ ហើយឈ្មោះ [redacted] សុខលី តែងតែបបួលខ្លួនមកលេងបងជីដូនមួយរបស់គេ ហើយបានបបួលខ្លួនប្រើប្រាស់ថ្នាំញៀនទៀតផង ខ្លួនប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះខាងលើនេះ នៅការ៉ាស់សាំងដែល ឈ្មោះ ហាក់ បានធ្វើការនោះបានចំនួន ៣ដង ខ្លួនមិនដឹងថានរណាជាអ្នកទិញថ្នាំញៀនទេ ខ្លួនគ្រាន់តែឈ្មោះ [redacted] សុខលី បបួលមកប្រើប្រាស់ តែពុំដែលឱ្យខ្លួនចេញលុយទេ។ ពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងជីដូនមួយរបស់ឈ្មោះ [redacted] សុខលី មកធ្វើការនៅជិតនេះទេ ទើបខ្លួនប្រើប្រាស់។

៤-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ខ្លួនជាមិត្តភក្តិឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] ថាវៈ ហើយឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted] ខ្លឹង ខ្លួន និងមិត្តភក្តឈ្មោះ [redacted] សារុន ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយរបស់ឈ្មោះ [redacted] សុខលី និងឈ្មោះ [redacted] ហាក់ ហើយឈ្មោះ [redacted] សុខលី តែងតែបបួលខ្លួនមកលេងបងជីដូនមួយរបស់គេ ហើយបានបបួលខ្លួនប្រើប្រាស់ថ្នាំញៀនទៀតផង ខ្លួនប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះអ្នកខាងលើ ដែលខ្លួនបានរៀបរាប់នោះនៅការ៉ាស់សាំងដែលឈ្មោះ ហាក់ បានធ្វើការនោះ បានចំនួន៥ដង ខ្លួនមិនដឹងថានរណាជាអ្នកទិញថ្នាំញៀនទេ ខ្លួន គ្រាន់តែឈ្មោះ [redacted] សុខលី បបួលមកប្រើប្រាស់ តែពុំដែលឱ្យខ្លួនចេញលុយទេ។ ពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងជីដូនមួយរបស់ឈ្មោះ ម៉ាន សុខលី មកធ្វើការនៅជិតនេះទេ ទើបខ្លួនប្រើប្រាស់។

៥-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខលី បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុអោយខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យតែប៉ុណ្ណោះ។ ខ្លួនពុំមែនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ [redacted] ខ្លឹង ខ្លួនគ្រាន់តែជាអ្នកភូមិនៅជិតការ៉ាស់សាំងរបស់គាត់ ហើយស្គាល់គាត់តាមរយៈផង



Scanned with CamScanner

ប្រុសខ្លួននៅត្បូងឃ្មុំ ហើយបងប្រុសជីដូនមួយខ្លួនឈ្មោះ [redacted] ហាក់ គាត់ជាបុគ្គលិកលក់សាំងឱ្យឈ្មោះ [redacted] ខ្លឹង ខ្លួន និងមិត្តភក្តិឈ្មោះ [redacted] ស៊ីណា និងឈ្មោះ [redacted] សារុន ឧស្សាហ៍នាំគ្នាមកលេងបងជីដូនមួយខ្លួនឈ្មោះ [redacted] ហាក់ ហើយបងជីដូនមួយខ្លួនបានបបួលពួកខ្លួនប្រើប្រាស់ថ្នាំញៀនបានចំនួន ២ដង នៅការ៉ាស់សាំង ដែលគាត់លក់នេះ ហើយរាល់ពេលទិញថ្នាំ គឺគាត់ជាអ្នកទៅទិញ ដោយពួកខ្លួនបានចូលលុយគ្នាម្នាក់អស់ចំនួន ១០,០០០ (មួយម៉ឺន) រៀល បាន១កញ្ចប់។ ខ្លួនមិនស្គាល់ថា បងខ្លួនទិញថ្នាំញៀនពីអ្នកណាទេ គ្រាន់តែធ្លាប់គាត់ប្រាប់ថាទិញពីឈ្មោះ [redacted] ពឿន តែប៉ុណ្ណោះ។ ពីមុនមក ខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែ៤ខែ ទៅ៥ខែ នេះទេ ដែលបងខ្លួនមកធ្វើការនៅជិតនេះទេទើបខ្លួនប្រើប្រាស់។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូតដូចជា ថ្នាំញៀន ចំនួន ០១កញ្ចប់តូច។

៦-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ហាក់ បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ ហើយចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យតែប៉ុណ្ណោះ។ ខ្លួនជាបុគ្គលិកចាក់សាំងរបស់ឈ្មោះ លី ខ្លឹង បានប្រហែល ៥ខែ ហើយពីមុនមកខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែខ្លួនមកធ្វើការនៅទីនេះទេ ហើយក៏បានស្គាល់ឈ្មោះ [redacted] ថាវៈ ហើយឈ្មោះ [redacted] ថាវៈ ក៏បានបបួលខ្លួនប្រើប្រាស់នៅការ៉ាស់សាំងដែលឈ្មោះ [redacted] ថាវៈ ធ្វើការ។ ខ្លួនបានប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ថាវៈ បានប្រហែល ៤ ទៅ ៥ដង ខ្លួនពុំធ្លាប់ស្គាល់ឈ្មោះ [redacted] ពឿន ពីមុនទេ ទើបតែខ្លួនមកធ្វើការនៅទីនេះ ខ្លួនបានស្គាល់ ហើយខ្លួនស្គាល់តាមរយៈឈ្មោះ [redacted] ថាវៈ ទេ ខ្លួនក៏ធ្លាប់ទិញថ្នាំញៀនពីឈ្មោះ ម៉ី ពឿន បានចំនួន ៥ដង។ បន្ទាប់មកឈ្មោះ [redacted] ពឿន ចេះតែឧស្សាហ៍ មកចាក់សាំង ហើយជជែកលេងជាមួយខ្លួនពីនេះពីនោះ ហើយគាត់ក៏បានប្រាប់ខ្លួនថាគាត់មានលក់ថ្នាំញៀន បានប្រហែល ២ ទៅ ៣ថ្ងៃ ខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] ពឿន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់ពីរនាក់ឈ្មោះ [redacted] សារុន បានចំនួន ៤ ដង ហើយខ្លួនទិញថ្នាំញៀនម្តងអស់ ២០,០០០ (ពីរម៉ឺន)រៀល ទៅ ៣០,០០០ (បីម៉ឺន) រៀល យកមកប្រើប្រាស់តែពីរនាក់ឈ្មោះ [redacted] សារុន ទេ។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២៣ វេលាម៉ោង ០៧យប់ ឈ្មោះ [redacted] ថាវៈ បានប្រាប់ខ្លួនថា ឈ្មោះ [redacted] ពឿន បានជិះម៉ូតូចូលមកការ៉ាស់សាំង ហើយបានយកថ្នាំញៀនជាច្រើនកញ្ចប់មកផ្ញើវា ដោយប្រាប់ថាទៅទិញបង្អែមញ៉ាំមួយភ្លែត ហើយវាក៏បានទទួលទុកឱ្យ រួចវាបានយកទៅ ដាក់នៅក្រោមតុគិតលុយរបស់ថៅកែខ្លួននៅការ៉ាស់សាំងដែលវាលក់នោះ បន្ទាប់មកនៅយប់ដដែលនោះវាបានអង្គុយចាំឈ្មោះ [redacted] ពឿន មកយកថ្នាំញៀន ប៉ុន្តែមិនឃើញគេមកយកថ្នាំញៀនសោះរហូតឈានចូលដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០នាទីរសៀល មានសមត្ថកិច្ចចុះមកឆែកឆេរ និងបានចាប់យកជាក់ស្តែងនៅការ៉ាស់សាំងដែលលក់ឱ្យឈ្មោះ [redacted] ខ្លឹង នោះគឺជាថ្នាំញៀនរបស់ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុប្រហែល ២៣ឆ្នាំទេ ខ្លួនសូមបញ្ជាក់ថា ថ្នាំញៀនដែលចាប់បាននៅការ៉ាស់សាំងរបស់ថៅកែខ្លួនឈ្មោះ [redacted] ខ្លឹង នោះគឺពុំមែនជាថ្នាំញៀនរបស់គាត់ទេ ហើយខ្លួនក៏ពុំដែលសមគំនិត ឬក៏លក់ដូរអ្វីទេ ហើយថៅកែខ្លួនក៏ពុំដែលស្គាល់ឈ្មោះ [redacted] ពឿន ដែរ។ សូមបញ្ជាក់ថា ថៅកែខ្លួនពុំដែលសម្រាកនៅការ៉ាស់សាំងនេះ គាត់គ្រាន់តែមកមើលពេលព្រឹកមួយភ្លែតៗតែប៉ុណ្ណោះ។



Scanned with CamScanner

៧-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ថាវៈ បានឆ្លើយថា ៖ ខ្លួនសូមបដិសេធចម្លើយទាំងអស់នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះមន្ត្រីនគរបាលយុត្តិធម៌ពុំបានអានកំណត់ហេតុឱ្យខ្លួនស្តាប់ទេ។ ចំពោះស្នាមមេដៃដែលខ្លួនបានផ្តិតនៅក្នុងកំណត់ហេតុនោះ គឺខ្លួនមានការភិតភ័យ តែប៉ុណ្ណោះ។ ខ្លួនពុំដែលធ្លាប់ប្រើប្រាស់ថ្នាំញៀនទេ ទើបតែស្គាល់ឈ្មោះ [redacted] ពឿន បានប្រហែលមួយខែ គឺកាលពីអំឡុងខែឧសភា ហើយស្គាល់តាមរយៈមិត្តភ័ក្ត។ បន្ទាប់មកឈ្មោះ [redacted] ពឿន ចេះតែឧស្សាហ៍មកចាក់សាំង ហើយជជែកលេងជាមួយខ្លួនពីនេះពីនោះ ហើយគាត់ក៏បានប្រាប់ខ្លួនថា គាត់មានលក់ថ្នាំញៀន បានប្រហែល ២ ទៅ ៣ថ្ងៃ ខ្លួនក៏បានទាក់ទងទៅឈ្មោះ [redacted] ពឿន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់ពីរនាក់ឈ្មោះ [redacted] សារុន បានចំនួន ៤ ដង ហើយខ្លួនទិញថ្នាំញៀនម្តងអស់ ២០,០០០ (ពីរម៉ឺន) រៀល ទៅ ៣០,០០០ (បីម៉ឺន) រៀល យកមកប្រើប្រាស់តែពីរនាក់ឈ្មោះ [redacted] សារុន ទេ។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៧ យប់ ឈ្មោះ ម៉ី ពឿន បានជិះម៉ូតូចូលមកកាវ៉ាស់សាំងហើយបានយកថ្នាំញៀនជាច្រើនកញ្ចប់មកផ្ញើរខ្លួន ដោយប្រាប់ថាទៅទិញបង្អែមញ៉ាំមួយភ្លែត ខ្លួនក៏បានទទួលទុកឱ្យ រួចខ្លួនបានយកទៅដាក់នៅក្រោមតុគិតលុយរបស់ថៅកែខ្លួននៅកាវ៉ាស់សាំង បន្ទាប់មកនៅយប់ដដែលនោះខ្លួនបានអង្គុយចាំឈ្មោះ ពឿន មកយកថ្នាំញៀន ប៉ុន្តែមិនឃើញគេមកយកថ្នាំញៀនសោះ រហូតឈានចូលដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០ នាទីរសៀល មានសមត្ថកិច្ចចុះមកឆែកឆេរ និងបានចាប់យកជាក់ស្តែងនៅកាវ៉ាស់សាំងដែលខ្លួនលក់ឱ្យឈ្មោះ [redacted] ខ្លឹង នោះគឺជាថ្នាំញៀនរបស់ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុប្រហែល ២៣ ឆ្នាំ ខ្លួនសូមបញ្ជាក់ថា ថ្នាំញៀនដែលចាប់បាននៅកាវ៉ាស់សាំងរបស់ថៅកែខ្លួនឈ្មោះ [redacted] ខ្លឹង គឺពុំមែនជាថ្នាំញៀនរបស់គាត់ទេ ហើយខ្លួនក៏ពុំដែលធ្លាប់ប្រើប្រាស់ ឬក៏លក់ដូរអ្វីទេ ហើយថៅកែខ្លួនក៏ពុំដែលស្គាល់ ឈ្មោះ [redacted] ពឿន ដែរ។ សូមបញ្ជាក់ថា ថៅកែខ្លួនពុំដែលសម្រាកនៅកាវ៉ាស់សាំងនេះ គាត់គ្រាន់តែមកមើលពេលព្រឹកមួយភ្លែតៗតែប៉ុណ្ណោះ។ នៅថ្ងៃឃាត់ខ្លួនសមត្ថកិច្ចបានដកហូតដូចជាទូរស័ព្ទម៉ាក OPPO ពណ៌ក្រហម មួយគ្រឿង និងថ្នាំញៀនចំនួន ៨៨ កញ្ចប់។

៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ជនជាប់ចោទឈ្មោះ [redacted] ថាវៈ, ឈ្មោះ [redacted] ហាក់ និងឈ្មោះ [redacted] សុខលី ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា និងឈ្មោះ [redacted] សារុន ពិតជាបានប្រព្រឹត្តអំពើ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ [redacted] ពឿន ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាដកមែន ដូច្នេះតំណាងអយ្យការ សូមរក្សាការចោទប្រកាន់ទុកនៅដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជននេះតាមច្បាប់។

៩-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ចម្លើយរបស់ជនជាប់ចោទដែលឆ្លើយនៅទីនេះ គឺមានភាពស៊ីសង្វាក់គ្នា ដោយនេះគឺជាចម្លើយដែលបង្ហាញពីការពិតខ្លាំង។ ដូច្នេះសូមឱ្យក្រុមប្រឹក្សាពិចារណា។ ចំពោះកំណត់ហេតុដែលឆ្លើយនៅប៉ូលីស គឺកូនក្តីខ្លួនបដិសេធទាំងអស់ ហើយគ្រឿងញៀនទាំងនោះ គឺជារបស់ឈ្មោះ [redacted] ពឿន។ សូមសំណូមពរឱ្យក្រុមប្រឹក្សាចាត់របៀបដើម្បីសួរតទល់រវាងកូនក្តីខ្លួន និងប៉ូលីស ហើយករណីដែលក្រុមប្រឹក្សានៅតែសម្រេចអំពីអង្គសេចក្តី ខ្លួនស្នើសុំឱ្យសម្រេចឱ្យកូនក្តីខ្លួនឈ្មោះ [redacted] ខ្លឹង រួចខ្លួនពីបទចោទ



Scanned with CamScanner

ដោយសារកូនក្តីខ្លួនមិនបានដឹងពីគ្រឿងញៀនទាំងនោះឡើយ ហើយលទ្ធផលតេស្តទឹកនោមក៏មិនមានឃើញវិជ្ជមានទៀត។

១០-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ខ្លួនសូមឱ្យក្រុមប្រឹក្សាសម្រេចដល់កូនក្តីខ្លួន ដោយពិចារណាអំពីចរិតលក្ខណៈនៃបទល្មើស។

១១-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងការពិនិត្យភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ឃើញថា ចម្លើយដែលកូនក្តីខ្លួនបដិសេធ គឺសមហេតុផល។ ដូច្នេះ សូមឱ្យក្រុមប្រឹក្សាសម្រេចផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនផង ដោយសារតែកូនក្តីខ្លួនជាអនីតិជន ហើយសារធាតុសុទ្ធនៃសារធាតុញៀនមានចំនួនតិច។

១២-តាមរបាយការណ៍លេខ ៨៤ រ.ប.ក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថាឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ, ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ, ឈ្មោះ [redacted] សារុន ភេទប្រុស អាយុ២០ ឆ្នាំ, ឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ, ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ, ឈ្មោះ [redacted] ថារៈ ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ ជាជនសង្ស័យក្នុងបទ រក្សាទុក ជួញដូរ, សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

១៣-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ គឺកើតចេញពីចេតនាយ៉ាងពិតប្រាកដរបស់ជនជាប់ចោទ ដែលធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសវិធានការការពារ បង្ការ និងបង្ក្រាប នូវការជួញដូរ ចែកចាយ និងប្រើប្រាស់នូវសារធាតុញៀន ជាបទ **“រក្សាទុក ជួញដូរ និងចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន”** ដែលបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤២ កថាខណ្ឌទី៣ ចំណុច២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៤-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ, ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] ថារៈ ភេទប្រុស អាយុ១៦ ឆ្នាំ គឺកើតចេញពីចេតនាយ៉ាងពិតប្រាកដរបស់ជនជាប់ចោទ ដែលធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសវិធានការការពារ បង្ការ និងបង្ក្រាប នូវការជួញដូរ ចែកចាយ និងប្រើប្រាស់នូវសារធាតុញៀន ជាបទ **“រក្សាទុក សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន”** ដែលបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

១៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៣០ ឆ្នាំ គឺកើតចេញពីចេតនាយ៉ាងពិតប្រាកដរបស់ជនជាប់ចោទ ដែលធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសវិធានការការពារ បង្ការ និងបង្ក្រាប នូវការជួញដូរ ចែកចាយ និងប្រើប្រាស់នូវសារធាតុញៀន ជាបទ **“សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន”** ដែលបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

១៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ គឺកើតចេញពីចេតនាយ៉ាងពិតប្រាកដរបស់ជនជាប់ចោទ ដែលធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសវិធានការការពារ បង្ការ និងបង្ក្រាប នូវការជួញដូរ ចែកចាយ និងប្រើប្រាស់នូវសារធាតុញៀន ជាបទ "**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**" ដែលបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៧-ជនជាប់ចោទឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ, ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ, ឈ្មោះ [redacted] ថារៈ ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ ជាអនីតិជនអាយុចាប់ពី១៤ ឆ្នាំឡើង ហើយកាលៈទេសៈនៃបទល្មើលតម្រូវ ដូច្នេះគប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទ តាមមាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

១៨-ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ, ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ និងឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៣០ ឆ្នាំ ជានីតិជនដែលអាចពិចារណា និងយល់ដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន ហើយលក្ខខណ្ឌគតិយុត្ត តម្រូវឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងត្រូវបានច្បាប់កំណត់ទុកជាបទល្មើសព្រហ្មទណ្ឌ។

១៩-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ ពីបទ៖ **រក្សាទុក ជួញដូរ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤២ កថាខណ្ឌទី៣ ចំណុច២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២០-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ, ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] ថារៈ ភេទប្រុស អាយុ១៦ ឆ្នាំ ពីបទ៖ **រក្សាទុក សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

២១-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ និងឈ្មោះ [redacted] សារុន ភេទប្រុស អាយុ៣០ ឆ្នាំ ពីបទ៖ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ។

២២-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២៣-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៤៣៧៥០/២៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣, លេខ៤៣៧៥១/២៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣, លេខ៤៣៧៥២ /២៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ និងលេខ៤៣៧៥៣/២៣ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបង្ហាញថាសំណាកជាប្រភេទម្សៅថ្លា ដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] សុខលី, ឈ្មោះ [redacted] ថារ:, ឈ្មោះ [redacted] ខ្លឹង និងឈ្មោះ [redacted] ហាក់, លទ្ធផលគឺវិជ្ជមានវត្ថុមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធចំនួន ៧៥.៣០ ភាគរយ នៃទម្ងន់សរុប។

២៤-វត្ថុតាងរួមមាន៖ ថ្នាំញៀនចំនួន ៧៨ កញ្ចប់ ទម្ងន់ ៥០,៦៥ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង, ថ្នាំញៀនចំនួន ១ កញ្ចប់ ទម្ងន់ ០,២២ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] សុខលី, ថ្នាំញៀនចំនួន ៣ កញ្ចប់ ទម្ងន់ ០,៦១ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] ហាក់, ថ្នាំញៀនចំនួន ៦ កញ្ចប់ ទម្ងន់ ២,៤៦ ក្រាម ជារបស់ ជនជាប់ចោទឈ្មោះ [redacted] ថារ:, ទូរស័ព្ទដៃចំនួន ៧ គ្រឿង, ដាវកែច្នៃ ចំនួន ១ ដើម, ម៉ូតូចំនួន ៣ គ្រឿង (ម៉ាក និក ពណ៌ស ស្លាកលេខ កំពង់ឆ្នាំង 1J-1366, ម៉ាកសង់ទ្រីម C125 ពណ៌ខ្មៅ ស្លាកលេខ ពោធិ៍សាត់ 1C-9304 និង ម៉ាកសង់ទ្រីម C125 ពណខ្មៅ ស្លាកលេខ កំពង់ឆ្នាំង 1E-9773), ប្រាក់ដុល្លារចំនួន ១,៣២៤ ដុល្លារអាមេរិក, ប្រាក់រៀល ចំនួន ១,១២៥.០០០ រៀល និងឧបករណ៍វេចខ្ចប់ថ្នាំញៀន និងឧបករណ៍ប្រើប្រាស់ថ្នាំញៀនមួយចំនួន គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

ក-ឈ្មោះ [redacted] ខ្លឹង ភេទប្រុស អាយុ៣០ ឆ្នាំ ជនជាតិខ្មែរ-ឥស្លាម (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៨ (ប្រាំបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០,០០០.០០០ (ម្ភៃលាន) រៀល ពីបទ រក្សាទុក ជួញដូរ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤២ កថាខណ្ឌទី៣ ចំណុច២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ឈ្មោះ [redacted] សារុន ហៅគួយ ភេទប្រុស អាយុ៣០ ឆ្នាំ ជនជាតិខ្មែរ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០,០០០.០០០ (ដប់លាន) រៀល។

គ-ឈ្មោះ [redacted] ស៊ីណា ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥,០០០.០០០ (ប្រាំលាន) រៀល។

ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការអត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ស្របតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

ឃ-ឈ្មោះ [redacted] សុខលី ភេទប្រុស អាយុ១៧ ឆ្នាំ ជនជាតិខ្មែរ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០.០០០ (ពីរលាន) រៀល។

ង-ឈ្មោះ [redacted] ហាក់ ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០.០០០ (ពីរលាន) រៀល។



Scanned with CamScanner

ច-ឈ្មោះ [redacted] ថារ: ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២,០០០.០០០ (ពីរលាន) រៀល។

ពីបទ រក្សាទុក សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ស្របតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ។

ឆ-ឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ (សាវតាមានដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៨ (ប្រាំបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០,០០០.០០០ (ម្ភៃលាន) រៀល ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិការត ឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ពឿន ភេទប្រុស អាយុ៣០ ឆ្នាំ (សាវតាមានដូចខាងលើ) តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៣-វត្ថុចាប់យករួមមាន៖** ថ្នាំញៀនចំនួន ៧៩ កញ្ចប់ ទម្ងន់ ៥០,៦៥ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] ខ្លឹង, ថ្នាំញៀនចំនួន ១ កញ្ចប់ ទម្ងន់ ០,២២ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] សុខលី, ថ្នាំញៀនចំនួន ៣ កញ្ចប់ ទម្ងន់ ០,៦១ ក្រាម ជារបស់ជនជាប់ចោទឈ្មោះ [redacted] ហាក់, ថ្នាំញៀនចំនួន ៦ កញ្ចប់ ទម្ងន់ ២,៤៦ ក្រាម ជារបស់ ជនជាប់ចោទឈ្មោះ [redacted] ថារ:, ទូរស័ព្ទដៃចំនួន ៧ គ្រឿង, ដាវកែច្នៃ ចំនួន ១ ដើម, ម៉ូតូចំនួន ៣ គ្រឿង (ម៉ាក និក ពណ៌ស ស្លាកលេខ កំពង់ឆ្នាំង 1J-1366, ម៉ាកសង់ទ្រឹម C125 ពណ៌ខ្មៅ ស្លាកលេខ ពោធិ៍សាត់ 1C-9304 និងម៉ាកសង់ទ្រឹម C125 ពណ៌ខ្មៅ ស្លាកលេខ កំពង់ឆ្នាំង 1E-9773), ប្រាក់ដុល្លារចំនួន ១,៣២៤ ដុល្លារអាមេរិក, ប្រាក់រៀលចំនួន ១,១២៥.០០០ រៀល និងឧបករណ៍វេចខ្ចប់ថ្នាំញៀន និងឧបករណ៍ប្រើប្រាស់ថ្នាំញៀនមួយចំនួន ត្រូវរឹបអូស។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខ្លឹង, ឈ្មោះ [redacted] សារុន, ឈ្មោះ [redacted] ស៊ីណា, ឈ្មោះ [redacted] ហាក់, ឈ្មោះ [redacted] ថារ:, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ពឿន និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤។

រក្សាសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ឆ្នាំង, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner